# ចំណេះដឹងមូលដ្ឋានពាក់ព័ន្ធនឹងការផ្សាយជាសាធារណៈនូវសាលក្រមសាលដីកាជប៉ុន

Ms. Suzuki Ichiko
សាស្ត្រាចារ្យ ICD - អតីតចៅក្រម

# មាតិកា

1 សេចក្តីពន្យល់ត្រួសៗអំពីប្រព័ន្ធតុលាការជប៉ុន

2 ស្តីពីតុលាការកំពូល

3 ស្តីពីសាលាក្រមជប៉ុន

# គោលបំណងនៃមេរៀននេះ

- ដើម្បីយល់ឱ្យបានកាន់តែច្បាស់នូវខ្លឹមសារនៃការបណ្តុះបណ្តាលនៅជប៉ុន
- ដើម្បីឱ្យដឹងកាន់តែស៊ីជម្រៅនូវប្រព័ន្ធកម្ពុជាតាមរយៈការប្រៀបធៀបនឹងប្រព័ន្ធរបស់ជប៉ុន

# សេចក្តីពន្យល់ត្រួសៗអំពីប្រព័ន្ធតុលាការជប៉ុន

# ប្រព័ន្ធអភិបាលកិច្ចរបស់ជប៉ុន (ការបែងចែកអំណាចទាំងបី)



# ឯករាជភាពរបស់ចៅក្រម

រដ្ឋធម្មនុញ្ញជប៉ុន

មាត្រា76

កថាខណ្ឌ1

សិទ្ធិតុលាការទាំងអស់ គឺជារបស់តុលាការជាន់ទាបដែលត្រូវបានបង្កើតឡើងដោយតុលាការកំពូល និងកំណត់ដោយច្បាប់។

កថាខណ្ឌ3

ចៅក្រមគ្រប់រូបអាចសម្រេចដោយឆន្ទានុសិទ្ធិឯករាជ្យតាមមនសិកាល្អរបស់ខ្លួន ហើយត្រូវចងដោយតែរដ្ឋធម្មនុញ្ញនេះ និងច្បាប់ប៉ុណ្ណោះ។

# ឯករាជភាពរបស់ចៅក្រម

រដ្ឋធម្មនុញ្ញជប៉ុន

មាត្រា78

មិនអាចដកហូតចៅក្រមពីមុខងារដោយក្រៅពីការចោទប្រកាន់ជាសាធារណៈបានឡើយ លើកលែងតែក្នុងករណីដែលចៅក្រមមានបញ្ហាសុខភាពខាងផ្លូវចិត្តឬផ្លូវកាយដែលមិនអាចបំពេញមុខងាររបស់ខ្លួនបាន ដែលត្រូវធ្វើតាមរយៈការជំនុំជម្រះ ហើយធ្វើសេចក្តីសម្រេច។ ការដាក់ទណ្ឌកម្មខាងវិន័យទៅលើចៅក្រម មិនអាចធ្វើឡើងដោយស្ថាប័នរដ្ឋបាលបានឡើយ។

# ប្រភេទតុលាការ

ទៅទស្សនកិច្ច



តុលាការកំពូល
**(Supreme Court)**

- តុលាការកំពូល (តូក្យូ)
- សាលាឧទ្ធរណ៍ (8)
  សាលាឧទ្ធរណ៍កម្មសិទ្ធិបញ្ញា (តូក្យូ)
- សាលាដំបូង(50)
- តុលាការគ្រួសារ (50)
- តុលាការសង្ខេប (438)



សាលាឧទ្ធរណ៍តំបន់តូក្យូ(Tokyo High-court),
សាលាដំបូងតូក្យូ (Tokyo District-Court)
និង តុលាការសង្ខេបតូក្យូ (Tokyo Summary Court)

ទៅទស្សនកិច្ច

# សមត្ថកិច្ចតាមដែនដី
## - សាលាឧទ្ធរណ៍-



# លក្ខណៈពិសេសនៃការជំនុំជម្រះរបស់ជប៉ុន (ចំណុចរួមរវាងការជំនុំជម្រះរឿងក្តីរដ្ឋប្បវេណី និងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ)

- ជាគោលការណ៍ ត្រូវធ្វើឡើងក្រោមគោលការណ៍ភាគី អ្វីៗដែលចង់ឱ្យតុលាការធ្វើការវិនិច្ឆ័យ ខាងភាគីត្រូវធ្វើការអះអាង។ ភស្តុតាងដែលចង់ឱ្យតុលាការពិនិត្យ ភាគីត្រូវដាក់ជូនតុលាការ (ចៅក្រមមិនប្រមូលភស្តុតាងដោយខ្លួនឯងឡើយ)។
- ចៅក្រមនិងភាគីត្រូវរៀបចំនូវចំណុចវិវាទ ឱ្យបានកាន់តែតិច កាន់តែល្អ ហើយចៅក្រមនឹងធ្វើការវិនិច្ឆ័យតែចំពោះចំណុចវិវាទទាំងនេះប៉ុណ្ណោះ។
- ចៅក្រមធ្វើការបកស្រាយច្បាប់ដែលចាំបាច់ ហើយធ្វើការវិនិច្ឆ័យតាមច្បាប់ និងធ្វើការទទួលស្គាល់អង្គហេតុ(សរសេរក្នុងសាលក្រមសាលដីកា។)

# ប្រព័ន្ធជំនុំជម្រះតាមថ្នាក់

- រឿងក្តីរដ្ឋប្បវេណី




- រឿងក្តីព្រហ្មទណ្ឌ



# ស្ដីពីតុលាការកំពូល

# តុលាការកំពូល

## តុលាការកំពូលជំនាន់ចាស់

ឆ្នាំ1890~ត្រូវបានបង្កើតឡើងក្រោមរដ្ឋធម្មនុញ្ញចាស់។

គេមិនបានបែងចែកតុលាការឱ្យដាច់ពីក្រសួងយុត្តិធម៌ទេ

យុត្តិសាស្រ្តតុលាការកំពូលជំនាន់ចាស់ ក៏នៅតែមានអានុភាពរហូតដល់បច្ចុប្បន្នដែរ។



## តុលាការកំពូល

ឆ្នាំ 1947~ត្រូវបានបង្កើតឡើងក្រោមរដ្ឋធម្មនុញ្ញបច្ចុប្បន្ន

ក្រសួងយុត្តិធម៌និងតុលាការត្រូវបានបែងចែកឱ្យដាច់ពីគ្នា។

ឯករាជភាពរបស់តុលាការត្រូវបានធានា។



ទៅទស្សនកិច្ច

# អង្គការលេខនៃ តុលាការកំពូល

- តុលាការកំពូល
  - ផ្នែកជំនុំជម្រះ(ប្រព័ន្ធជំនុំជម្រះដោយក្រុមប្រឹក្សា)
    - សាលសវនាការធំ
    - សាលសវនាការតូចទី១
    - សាលសវនាការតូចទី២
    - សាលសវនាការតូចទី៣
  - ផ្នែករដ្ឋបាលតុលាការ (អង្គប្រជុំនៃចៅក្រម)

# គណកម្មការដែលមាននៅក្នុងតុលាការ

នៅក្នុងតុលាការ គេបានបង្កើតគណកម្មការផ្សេងៗដើម្បីសិក្សាស្រាវជ្រាវ ឬធ្វើការពិនិត្យអំពីរដ្ឋបាលតុលាការ ជាអាទិ៍។

ឧទាហរណ៍អំពីគណកម្មការដែលគេបានបង្កើតនៅក្នុងតុលាការកំពូល

- គណកម្មការផ្តល់អនុសាសន៍អំពីការបង្កើតបទដ្ឋានគតិយុត្តិរដ្ឋប្បវេណី
- គណកម្មការផ្តល់អនុសាសន៍អំពីការបង្កើតបទដ្ឋានគតិយុត្តិព្រហ្មទណ្ឌ
- គណកម្មការយុត្តិសាស្ត្រតុលាការ

សូមស្តាប់សេចក្តីពន្យល់របស់តុលាការកំពូល

# ចៅក្រមតុលាការកំពូល



ប្រធានតុលាការកំពូល(1នាក់)



ចៅក្រមតុលាការកំពូល(14 នាក់)

- បច្ចុប្បន្ន ក្នុងចំណោម 15នាក់ មានស្ត្រី 3នាក់ បុរស 12នាក់
- បច្ចុប្បន្ន

មកពីចៅក្រម 6នាក់

មកពីមេធាវី 3នាក់

មកពីបញ្ញវន្ត 2នាក់

មកពីព្រះរាជអាជ្ញា 2នាក់

មកពីមន្ត្រីរដ្ឋបាល 2នាក់

# សាលសវនាការធំ និង សាលសវនាការតូច




- ការជំនុំជម្រះក្នុងសាលសវនាការធំ ធ្វើឡើងដោយចៅក្រម 15នាក់ (កូរ៉ុម 9នាក់)
- ការជំនុំជម្រះក្នុងសាលសវនាការតូច ធ្វើឡើងដោយចៅក្រម 5នាក់ (កូរ៉ុម 3នាក់)
- ពេលធ្វើការវិនិច្ឆ័យពាក់ព័ន្ធនឹងរដ្ឋធម្មនុញ្ញ ត្រូវជំនុំជម្រះនៅសាលសវនាការធំ។

# មន្ត្រីស្រាវជ្រាវនៃតុលាការកំពូល

- ការិយាល័យមន្ត្រីស្រាវជ្រាវនៃតុលាការកំពូល គឺជាកន្លែងមួយសម្រាប់ចៅក្រមប្តូរចូលធ្វើការងារ។
- មន្ត្រីស្រាវជ្រាវនៃតុលលាការកំពូល ទទួលបញ្ជាពីចៅក្រមតុលាការកំពូល ធ្វើការស្រាវជ្រាវចាំបាច់ជាអាទ៍ ដើម្បីធ្វើការជំនុំជម្រះនិងសម្រេចសេចក្តីអំពីរឿងក្តី។(ច្បាប់តុលាការ មាត្រា57)
- ប្រភេទការិយាល័យមន្ត្រីស្រាវជ្រាវនៃតុលាការកំពូល
  - ការិយាល័យមន្ត្រីស្រាវជ្រាវជាន់ខ្ពស់(2នាក់)
  - ការិយាល័យស្រាវជ្រាវអំពីរដ្ឋប្បវេណី(ខ្ទង់ 20នាក់)
  - ការិយាល័យស្រាវជ្រាវអំពីរដ្ឋបាល(ខ្ទង់ 10នាក់)
  - ការិយាល័យស្រាវជ្រាវអំពីព្រហ្មទណ្ឌ(ខ្ទង់ 8នាក់)

សូមស្តាប់សេចក្តីពន្យល់

# ការជំនុំជម្រះបណ្តឹងសាទុក្ខ

- នៅក្នុងបណ្តឹងរដ្ឋប្បវេណីក៏ដោយ បណ្តឹងព្រហ្មទណ្ឌក៏ដោយ ការជំនុំជម្រះបណ្តឹងសាទុក្ខ គឺជាការវិនិច្ឆ័យទៅលើអង្គច្បាប់។

  ប៉ុន្តែក្នុងករណីនៃបណ្តឹងព្រហ្មទណ្ឌ បើសិនជាមានការទទួលស្គាល់អង្គហេតុដោយមានការភាន់ច្រឡំធ្ងន់ធ្ងរ ហើយបើសិនជាមិនបដិសេធចោលនូវសាលដីកាដើមទេ នឹងផ្ទុយនឹងយុត្តិធម៌យ៉ាងខ្លាំង ជាអាទិ៍ ក្នុងករណីនេះ តុលាការកំពូលក៏ត្រូវធ្វើការវិនិច្ឆ័យអំពីអង្គហេតុដោយខ្លួនដែរ។

- ភាគតិចណាស់ដែលតុលាការកំពូលបើកសវនាការទាញហេតុផលដោយផ្ទាល់មាត់។
- ប្រភេទនៃសាលដីកា

  ①លើកបណ្តឹងសាទុក្ខចោល

  ②ច្រានបណ្តឹងសាទុក្ខចោល

  ③បដិសេធចោលនូវសាលដីកាដើម

- ការចាត់ចែងក្រោយពេលបដិសេធចោលនូវសាលដីកាដើម

  ①ការបញ្ជូន ឬផ្ទេរទៅតុលាការដើម

  ②ការវិនិច្ឆ័យដោយខ្លួនឯង

# សិទ្ធិពិនិត្យអធម្មនុញ្ញភាព

- រដ្ឋធម្មនុញ្ញជប៉ុន មាត្រា81

តុលាការកំពូល គឺជាតុលាការចុងក្រោយដែលមានសិទ្ធិសម្រេចថា តើច្បាប់ បទបញ្ជា បទដ្ឋានគតិយុត្តិ ឬការចាត់ចែងអ្វីមួយស្របនឹងរដ្ឋធម្មនុញ្ញ ឬមិនស្រប។

- គេអាចគិតថា តុលាការជាន់ទាបក៏មានសិទ្ធិពិនិត្យអធម្មនុញ្ញភាពដែរ។
- តុលាការមិនអាចធ្វើការវិនិច្ឆ័យថា ច្បាប់ណាមួយដែលមានលក្ខណៈអរូបីថា ច្បាប់នោះផ្ទុយនឹងរដ្ឋធម្មនុញ្ញ ដោយឃ្លាតចាកពីអង្គហេតុជាក់លាក់បានឡើយ។

# ការពិនិត្យបណ្ដឹងសាទុក្ខក្នុងរឿងក្ដីរដ្ឋប្បវេណី (តុលាការកំពូល)

- ប្រភេទនៃបណ្ដឹងសាទុក្ខ

  ①ការដាក់ពាក្យបណ្ដឹងសាទុក្ខ

  ②ការទទួលពាក្យបណ្ដឹងសាទុក្ខ(បណ្ដឹងសាទុក្ខដោយឆន្ទានុសិទ្ធិ)

- ក្នុងករណីដែលមាននីតិវិធីពិសេសណាមួយផ្ទុយនឹងរដ្ឋធម្មនុញ្ញ អាចប្ដឹងសាទុក្ខបាន(មូលហេតុនៃការប្ដឹងសាទុក្ខ ត្រូវបានកំណត់ដោយច្បាប់ៗ)។

- ក្នុងករណីដែលមានភាពផ្ទុយនឹងយុត្តិសាស្ត្រតុលាការ ឬមានការចាំបាច់បកស្រាយច្បាប់សំខាន់ណាមួយ អាចប្ដឹងសាទុក្ខបាន(មូលហេតុនៃការប្ដឹងសាទុក្ខត្រូវបានកំណត់ដោយច្បាប់ៗ)។

# ការពិនិត្យបណ្តឹងសាទុក្ខក្នុងរឿងក្តីព្រហ្មទណ្ឌ (តុលាការកំពូល)

- ក្នុងករណីដែលមានភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬផ្ទុយនឹងយុត្តិសាស្រ្តតុលាការ ជាអាទិ៍ អាចប្តឹងសាទុក្ខបាន(មូលហេតុនៃការប្តឹងសាទុក្ខ ត្រូវបានកំណត់ដោយច្បាប់ៗ)។

# ស្តីពីសាលក្រម

# សាលក្រមជប៉ុន

- ចៅក្រមទទួលបន្ទុកធ្វើការវិនិច្ឆ័យ ហើយសរសេរសាលក្រមដោយខ្លួនឯង(ម្នាក់ ឬ បីនាក់)
- បន្ទាប់ពីបានប្រឡងជាប់ក្នុងវគ្គប្រឡងដើម្បីធ្វើជាអ្នកច្បាប់(ចៅក្រម ព្រះរាជអាជ្ញា មេធាវី) ហើយក្នុងកំឡុងពេលទទួលការបណ្តុះបណ្តាលរួមអំពីច្បាប់ គេបង្រៀនអំពីវិធីសរសេរសាលក្រម។
- បន្ទាប់ពីបានធ្វើជាចៅក្រមហើយ ក៏ត្រូវទទួលការបណ្តុះបណ្តាលជាពិសេសស្តីពីការសរសេរសាលក្រម តាមរយៈការងារដែរ (OJT=On the Job Training)។
- ពេលសរសេរសាលក្រម ក្រៅពីការអានរឿងក្តី ត្រូវតែស្រាវជ្រាវអំពីយុត្តិសាស្ត្រតុលាការកំពូល សាលក្រមសាលដំបូងគំរូល្អៗរបស់តុលាការជាន់ទាប និងទ្រឹស្តីច្បាប់ ជាដើម ទៅតាមការចាំបាច់។

# បើសិនជាប្រជាពរដ្ឋចង់អានសាលក្រមសាលដីកា .....

- ទៅតុលាការ ហើយសុំមើលសំណុំរឿង ឬសុំថតចម្លង (មានការកំណត់លក្ខខ័ណ្ឌដោយច្បាប់)
- ស្វែងរកសាលក្រមសាលដីកាតាមរយៈគេហទំព័ររបស់តុលាការ (មួយចំនួនមានជាភាសាអង្គ្លេស)
- ស្វែងរកសាលក្រមសាលដីកាតាមរយៈសេវាកម្មឯកជនសម្រាប់ស្វែងរកសាលក្រមសាលដីកា
- អានកម្រងយុត្តិសាស្ត្រតុលាការ កម្រងសាលក្រមសាលដីកាគំរូល្អៗ ដែលតុលាការក៏ពូលបានផ្សាយជាសាធារណៈ
- អានទស្សនាវដ្ដីច្បាប់ដែលលក់តាមផ្សារ
- អានសៀវភៅលក់តាមផ្សារ

# បើសិនជាចៅក្រមចង់ស្រាវជ្រាវសាលក្រមសាលដីកាដទៃ .....

- ស្វែងរកសាលក្រមសាលដីកាតាមរយៈគេហទំព័ររបស់តុលាការ(មួយចំនួនមានជាភាសាអង់គ្លេស)
- ស្វែងរកសាលក្រមសាលដីកាតាមរយៈសេវាកម្មឯកជនសម្រាប់ស្វែងរកសាលក្រមសាលដីកា
- អានកម្រងយុត្តិសាស្រ្តតុលាការ កម្រងសាលក្រមសាលដីកាគំរូល្អៗ ដែលតុលាការកំពូលបានផ្សាយជាសាធារណៈ
- អានទស្សនាវដ្តីច្បាប់ដែលលក់តាមផ្សារ
- អានសៀវភៅលក់តាមផ្សារ
- អានការបកស្រាយរបស់មន្រ្តីស្រាវជ្រាវនៃតុលាការកំពូល

# ការផ្សាយជាសាធារណៈនូវសាលក្រម សាលដីកានៅជប៉ុន

- នៅជប៉ុន គេអាចមើលសាលក្រមសាលដីកាបាន តាមរយៈនីតិវិធីកំណត់មួយនៅតុលាការ ហេតុនេះហើយ ជាគោលការណ៍ គឺគេផ្សាយជាសាធារណៈនូវសាលក្រមសាលដីកានៃគ្រប់រឿងក្តី។
- តុលាការធ្វើការជ្រើសរើសយ៉ាងសកម្ម នូវសាលដីកាដែលគេទុកជាយុត្តិសាស្រ្តតុលាការ។

សូមស្តាប់សេចក្តីពន្យល់របស់តុលាការកំពូល

# ការផ្សាយជាសាធារណៈនូវសាលក្រម សាលដីកា ដោយឯកជន

ក្រុមហ៊ុនបោះពុម្ពផ្សាយឯកជនដែលបានទទួលសាលដីកាពីតុលាការ នឹងបោះពុម្ពផ្សាយនូវកម្រងសាលដីកាទាំងនោះ
(ភាគច្រើន មានភ្ជាប់ទាំងការបកស្រាយរបស់អ្នកស្រាវជ្រាវច្បាប់ ឬអ្នកច្បាប់ ជាអាទិ៍ផងដែរ)

→"Hanreijiho" "Hanrei Times" ជាអាទិ៍

ទៅទស្សនកិច្ចនៅក្រុមហ៊ុន Hanreijiho ។



# Thank you.

ICD

International Cooperation Department